ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

របាយការណ៍សង្ខេប
ស្ដីពី
សកម្មភាពការងាររបស់រដ្ឋសភា
ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧

- សូមគោរពសម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា
- ឯកឧត្តមអនុប្រធានទី២ រដ្ឋសភា ជាទីរាប់អានដ៏ជ្រាលជ្រៅ !
- សម្ដេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភា ដ៏ឧត្ដុង្គឧត្ដម !
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងភ្ញៀវកិត្តិយសទាំងអស់ជាទីរាប់អាន !

ជាបឋមក្នុងនាមសម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា និងក្នុងនាមទូលបង្គំខ្ញុំផ្ទាល់ សូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅចំពោះវត្តមានរបស់សម្ដេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភាទាំងអស់ ដែលបានអញ្ជើញចូលរួមពិធីបើកសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៧ ក្រោយពីបានចុះបំពេញភារកិច្ចនៅតាមមណ្ឌលរាជធានី ខេត្ត និងបំពេញបេសកកម្មផ្សេងៗ នាពេលចន្លោះសម័យប្រជុំរយៈពេល ៣ ខែ កន្លងមកនេះ។

អាស្រ័យដោយបានការអនុញ្ញាតពីសម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា ទូលបង្គំ ខ្ញុំកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ នៃរដ្ឋសភា សូមអនុញ្ញាតទូលថ្វាយ និងជម្រាបជូនអង្គសភា សាធារណជន និងជនរួមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបនូវរបាយការណ៍សង្ខេបស្ដីពី សកម្មភាពការងាររបស់រដ្ឋសភា នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧ ដែលមានជាអាទិ៍ សកម្មភាពការងាររបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា សកម្មភាពការងារសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ សកម្មភាពការងារការទូតសភា សកម្មភាពការងារថ្នាក់ដឹកនាំរដ្ឋសភា និងសកម្មភាពការងារគណៈកម្មការនានា នៃរដ្ឋសភា។

## I- សកម្មភាពការងាររួមរបស់រដ្ឋសភា

❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍

នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា ដោយមានការចូលរួមពីទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ ឯកឧត្តម វង សូត អនុប្រធានទី២ និងឯកឧត្តម

លោកជំទាវ សមាជិក សមាជិកាគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ចំនួន ៣ លើក ដោយបានពិនិត្យនិងអនុម័តលើរបៀបវារៈសំខាន់ៗ ជាអាទិ៍៖

1. ការជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២ រូប។
2. សេចក្តីព្រាងច្បាប់ស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក។
3. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល។
4. សេចក្តីស្នើសុំរដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលចំនួន ៣រូប។
5. ការសម្រេចលើកាលបរិច្ឆេទសម្រាប់បើកសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញចំនួន ២លើក។

❖ **សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ**

ក្នុងរយៈពេលនេះដែរ រដ្ឋសភាបានបើកសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ដោយមានការចូលរួមពីទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ ឯកឧត្តម **វង សូត** អនុប្រធានទី២ និងសម្តេចព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភា ចំនួន ២លើក ៖

**សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញលើកទី១** បានប្រព្រឹត្តិទៅកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២៤ ដោយបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលចំនួន ៣រូប រួមមានឯកឧត្តម **ហ៊ុន ម៉ានី** ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ, ឯកឧត្តម **ស្រ៊ី ថាមរុង្គ** ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងឯកឧត្តម **ប៉ែន វិបុល** ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។

**សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញលើកទី២** បានប្រព្រឹត្តទៅកាលពីថ្ងៃទី១ ខែ មីនា ឆ្នាំ២០២៤ ដោយបាន៖

- បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ២រូប គឺៈ ឯកឧត្តម **សុខ ឥសាន** និង ឯកឧត្តម **ហេង ហាលីម** ជាសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៥។
- អនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល។ សេចក្តីព្រាងច្បាប់នេះមានគោលបំណងទប់ស្កាត់ការឧបត្ថម្ភធនដល់ការនេសាទខុសច្បាប់គ្មានរបាយការណ៍និងគ្មានបញ្ញត្តិ ការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិជាសកល និងធានានូវនិរន្តរភាពធនធានជលផលសមុទ្រក្នុងកម្រិតសកល តំបន់ និងរដ្ឋសមាជិកនីមួយៗ។
- បានអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក។ សេចក្តីព្រាងច្បាប់នេះមានគោលបំណងធានាការគ្រប់គ្រង និងការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា រក្សាសណ្តាប់ធ្នាប់និងធានាសុវត្ថិភាព សន្តិសុខនៃការដឹកជញ្ជូនតាមផ្លូវទឹក ការកសាងនិងថែ

រក្សាការពារហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនិងការការពារបរិស្ថាន និងការផ្តល់កាលានុវត្តភាពវិនិយោគ និងការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ សមធម៌ និងតម្លាភាពសម្រាប់ពាណិជ្ជកម្មជាតិ និងអន្តរជាតិក្នុងការទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

❖ **ការងារជាតំណាង**

នៅចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧ ថ្នាក់ដឹកនាំរដ្ឋសភា គណៈកម្មការនានា និងសមាជិក សមាជិការដ្ឋសភាគ្រប់រូប បានបំពេញការងារនៅតាមមណ្ឌលរាជធានី ខេត្តនានា និងនៅទូទាំងប្រទេសយ៉ាងសស្រាក់សស្រាំ ដើម្បីចុះសួរសុខទុក្ខប្រជាពលរដ្ឋផ្ទាល់នៅតាមមូលដ្ឋាន ចូលរួមក្នុងកម្មវិធីនានា ការងារសង្គមដូចជាការឧបត្ថម្ភដល់ប្រជាជនជួបការលំបាក ចូលរួមដោះស្រាយសំណូមពរនិងសំណើផ្សេងៗរបស់ប្រជាពលរដ្ឋ ជួយអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ ជាអាទិ៍៖

-សម្តេចរដ្ឋសភាធិបតីប្រធានរដ្ឋសភា ទូលបង្គំ ខ្ញុំអនុប្រធានទី១ និងឯកឧត្តមអនុប្រធានទី២ រដ្ឋសភា បានចុះមូលដ្ឋានចំនួន ១៣លើក។

-គណៈកម្មការនានានៃរដ្ឋសភា បានចុះបំពេញបេសកកម្មចំនួន ១៤លើក ក្នុងនោះ៖

- **គណៈកម្មការទី១** ចំនួន ១លើក នៅខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។
- **គណៈកម្មការទី២** ចំនួន ៥លើក នៅខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។
- **គណៈកម្មការទី៣** ចំនួន ១លើក នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។
- **គណៈកម្មការទី៤ និងគណៈកម្មការទី៥** ចំនួន ១លើក នៅខេត្តជាប់ព្រំដែនប្រទេសថៃ រួមមាន ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន និងខេត្តព្រះវិហារ។
- **គណៈកម្មការទី៦** ចំនួន ១លើក នៅខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។
- **គណៈកម្មការទី៧** ចំនួន ១លើក នៅខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។
- **គណៈកម្មការទី៨** ចំនួន ២លើក គឺ លើកទី១ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប និងលើកទី២ នៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង។
- **គណៈកម្មការទី៩** ចំនួន ២លើក គឺ លើកទី១ នៅខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងលើកទី២ នៅខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគិរី។

- ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី បានចុះមូលដ្ឋានចំនួន ៨លើក។

- សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភាគ្រប់រូប បានចុះតាមមណ្ឌលរាជធានី ខេត្តនានា និងនៅទូទាំងប្រទេស ដើម្បីចុះសួរសុខទុក្ខប្រជាពលរដ្ឋផ្ទាល់នៅតាមមូលដ្ឋានយ៉ាងច្រើន ដូចមានកំណត់ក្នុងរបាយការណ៍ពិស្តារស្តីពី សកម្មភាពការងាររបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧។

❖ ការងារការទូតសភា

ក្នុងរយៈពេលនេះដែរ រដ្ឋសភានីតិកាលទី៧ បានបំពេញការងារការបរទេសយ៉ាងសកម្ម ទាំងក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី សំដៅពង្រឹង ពង្រីក និងលើកកម្ពស់វិស័យការទូតសភា។ ការងារការទូតសភានេះជាកិច្ចការការបរទេសរបស់សភាមួយដ៏សំខាន់ ដែលបានរួមចំណែកដល់ការពង្រឹង ពង្រីក និងលើកកម្ពស់ទំនាក់ទំនង ចំណងមិត្តភាព និងសហប្រតិបត្តិជាមួយសភា និងរដ្ឋាភិបាលនៃប្រទេសនានា ដៃគូអភិវឌ្ឍន៍ និងអង្គទូតបរទេសនានា ព្រមទាំងពង្រីក និងលើកកម្ពស់តួនាទីសភាកម្ពុជាក្នុងវេទិកាអន្តរសភានានា និងលើកកម្ពស់យន្តការពហុភាគី មានលក្ខណៈបើកចំហ និងបរិយាប័ន្ន និងគោរពនូវសណ្តាប់ធ្នាប់អន្តរជាតិដោយផ្អែកលើច្បាប់ ដើម្បីជានាការពារសុខសន្តិភាព ស្ថិរភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ វិស័យការទូតសភាបានគ្រប់ដណ្តប់លើគ្រប់វិស័យសំខាន់ៗជាច្រើន រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម បរិស្ថាន ទេសចរណ៍ អប់រំ និងវប្បធម៌ ព្រមទាំងការលើកកម្ពស់សិទ្ធិស្ត្រី ការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី និងសមភាពយេនឌ័រ ជាដើម។

នាពេលបច្ចុប្បន្ន ក្នុងបរិបទនៃសភាពការណ៍ពិភពលោកមានការប្រែប្រួលឥតឈប់ឈរ មានភាពស្មុគស្មាញ និងពិបាកស្មានទុកជាមុន ព្រមទាំងមានហានិភ័យខ្ពស់ដោយសារការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ ការបែងចែកសេដ្ឋកិច្ចអន្តរជាតិ និងការកាត់ផ្តាច់ខ្សែច្រវាក់ផ្គត់ផ្គង់បណ្តាលមកពីភូមិសាស្ត្រនយោបាយ ព្រមទាំងសង្គ្រាមដែលបានផ្ទុះឡើងនៅតាមតំបន់ជាច្រើននៃពិភពលោក វិស័យការទូតសភាបាននិងកំពុងដើរតួនាទីដ៏សំខាន់ខ្លាំង ដើម្បីពង្រឹងសុខសន្តិភាព ពង្រឹងគោលការណ៍ពហុភាគីនិយម ដោយផ្អែកលើច្បាប់ ប្រកបដោយភាពបរិយាប័ន្នា និងការទទួលខុសត្រូវ។ ក្នុងន័យនេះ ការពង្រឹងសមត្ថភាពការទូតសភាមានសារៈសំខាន់ខ្លាំង ដើម្បីស្វែងរកនិងត្រៀមជាស្រេចនូវវិធីសាស្ត្រ ក្នុងការដោះស្រាយបញ្ហាប្រកួតប្រជែងភូមិសាស្ត្រនយោបាយដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ននេះ។ ជាមួយគ្នានេះ ជាការពង្រឹងនូវការផ្សារភ្ជាប់រវាងការទូតសភា ការទូតរដ្ឋាភិបាល និងការទូតប្រជាជន ជាកត្តាគន្លឹះ និងចាំបាច់បំផុត។

នៅក្នុងវិស័យការទូតសភានេះ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ ឯកឧត្តម **វង សូត** អនុប្រធានទី២ និងសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភា បានទទួលជួបសវនាការ ជាមួយភ្ញៀវអន្តរជាតិ និងអង្គការស្ថាប័ននានា ដែលមានជាអាទិ៍៖

***សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា** បានទទួលជួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា ភ្ញៀវជាតិ-អន្តរជាតិ និងអង្គការនានាចំនួន១២លើក ជាអាទិ៍៖

- ឯកឧត្តមបណ្ឌិត **សាន់តូ ដាម៉ូស៊ូម៉ាតូ** (Santo Darmosumarto) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥណ្ឌូនេស៊ី
- ឯកឧត្តម **ចាស្ទីន ខេវិន វ៉ាយអេត** (Justin Kevin Whyatt) ឯកអគ្គរដ្ឋទូតអូស្ត្រាលី
- ឯកឧត្តម **អ៊ីមេណេហ្ស៊ីលដូ គុប៉ា ឡូប៉េស** (Ermenegildo Kupa Lopes) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត
- ឯកឧត្តម **ហ្សាន ហ្សាហ៉ាឌីល** (Jan Zahradil) សមាជិកសភាអឺរ៉ុប និងជាអនុប្រធានទី១ នៃគណៈកម្មការពាណិជ្ជកម្មអន្តរជាតិ នៃសភាអឺរ៉ុប

- ឯកឧត្តម **ចូហាន់ ស្ទីងនីហ្គ័រ** (Johannes Steiniger) សមាជិកសភាសហព័ន្ធអាល្លឺម៉ង់
- លោកជំទាវ **លឿកា រ៉ូទ្រីហ្គេស បារីយ៉ូស** (Liurka Rodriguez Barrios) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋគុយបា
- ឯកឧត្តម **ហ្សាហៀរូឌីន បាបា ថាហ៊ីម** (Zaheeruddin Babar Thaheem) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន
- ឯកឧត្តម **ធីប័រ បាឡូកឌី** (Tibor Baloghdi) ឯកអគ្គរដ្ឋទូត នៃប្រទេសហុងគ្រី
- លោកស្រី **រ៉ូអ៊ីដា អែលហាក** (Rouieda El Hage) តំណាងប្រចាំប្រទេសនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
- អ្នកវាយតម្លៃឯករាជ្យអំពីគម្រោង និងសកម្មភាពរបស់មជ្ឈមណ្ឌលសភាអាស៊ី (PCAsia)
- ក្រុមហ៊ុនមិត្តហ្វូន (Metfone) និងសមាគមពាណិជ្ជករគ្រឿងអលង្ការនិងត្បូងមានតម្លៃកម្ពុជា។

នៅក្នុងជំនួបពិភាក្សាការងារខាងលើនេះ **សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា** តែងតម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋនិងប្រទេសជាតិជាធំ ដោយបានប្រើប្រាស់យន្តការវិស័យការទូតសភានេះ សំដៅរឹតចំណងទំនាក់ទំនង មិត្តភាព និងសហប្រតិបត្តិការឱ្យកាន់តែសកម្ម ជាមួយសមភាគីទាំងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងនោះការទាក់ទាញអ្នកវិនិយោគ អ្នកទេសចរ ការបណ្តុះបណ្តាលធនធានមនុស្ស ការពង្រឹងសមត្ថភាពមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ការស្វែងរកការគាំទ្រដល់ការធ្វើទំនើបកម្មរដ្ឋសភារបស់យើងទៅជាសភាឌីជីថល សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារ បម្រើប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

**អង្គសភាដ៏ឧត្តុង្គឧត្តម!**

ជាមួយគ្នានេះ តបតាមការអញ្ជើញរបស់លោកជំទាវ **យ៉ាអែល ប្រូន ពីវេ** (Yaël Braun-Pivet) ប្រធានរដ្ឋសភានៃសាធារណរដ្ឋបារាំង **សម្តេចរដ្ឋសភាធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋបារាំង និងចូលរួមកិច្ចប្រជុំកំពូលប្រធានសភាជាស្ត្រី ពីថ្ងៃទី២ ដល់ថ្ងៃទី១១ ខែមីនា ដោយទទួលបានលទ្ធផលគួរជាទីមោទន។

ក្នុងដំណើរទស្សនកិច្ចផ្លូវការនេះ **សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា** បានជួបពិភាក្សាការងារជាមួយលោកជំទាវប្រធានរដ្ឋសភា និងជួបសន្ទនាជាមួយឯកឧត្តម **អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតីបារាំងនៃសាធារណរដ្ឋបារាំង ដើម្បីបន្តពង្រឹង ពង្រីកបន្ថែមទៀតនូវទំនាក់ទំនងដ៏ល្អនិងជាប្រវត្តិសាស្ត្រកម្ពុជា-បារាំងឱ្យកាន់តែរឹងមាំជិតស្និទ្ធថែមទៀត ជាពិសេសបានពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរដ្ឋសភាប្រទេសទាំងពីរឱ្យកាន់តែសកម្ម និងគ្រប់ជ្រុងជ្រោយ ទាំងក្របខណ្ឌទ្វេភាគី និងពហុភាគី។

ជាមួយគ្នានេះដែរសម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារផ្លូវការនិងជួបសន្ទនាក្រៅផ្លូវការជាមួយថ្នាក់ដឹកនាំប្រតិភូចូលរួមកិច្ចប្រជុំ ដើម្បីពង្រឹងវិស័យការទូតសភា និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសទាំងនោះឱ្យកាន់តែជិតស្និទ្ធ ក្នុងគោលបំណងស្វែងរកផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងប្រទេសជាតិ លើកកម្ពស់វិស័យការទូតសភាជាមួយប្រទេសនិងដៃគូជាមិត្តមកពីគ្រប់ទ្វីបក្នុងពិភពលោក រួមមាន៖

- បានជួបពិភាក្សាការងារជាមួយលោក ប្រ៊ុយណូ ហ្វូស (Bruno Fuchs) អគ្គប្រតិភូនៃសភានិយាយភាសាបារាំង (Assemblee Parliamentaire de la Francophonie-APF) និងសហការីដើម្បីរឹតចំណងសាមគ្គីភាពបន្ថែមទៀតរវាងរដ្ឋសភាកម្ពុជា និងបណ្ដាប្រទេសនិយាយភាសាបារាំង។
- បានជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ ទូលៀ អ៊ែកសិន (Tulia Ackson) ប្រធានសភាតង់ហ្សានី និងជាប្រធានសហភាពអន្តរសភា(IPU)។ ភាគីទាំងពីរបានផ្លាស់ប្ដូរយោបល់គ្នាទាក់ទងនឹងស្ថានការណ៍តំបន់និងអន្តរជាតិ ជាពិសេសទំនាក់ទំនងរវាងកម្ពុជា-តង់ហ្សានី និងកិច្ចសហការក្នុងក្របខណ្ឌ IPU ដោយបានកោតសរសើរកម្ពុជាចំពោះការចូលរួមយ៉ាងសកម្មនៅក្នុងក្របខណ្ឌនេះ។ លោកជំទាវប្រធានសភាសភាតង់ហ្សានី និងជាប្រធាន IPU ក៏បានអញ្ជើញសម្ដេចរដ្ឋសភាធិបតីទៅបំពេញទស្សនកិច្ចនៅប្រទេសតង់ហ្សានី នៅពេលវេលាសមស្របណាមួយ ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងសភា និងប្រជាជននៃប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅថែមទៀត។

បន្ថែមទៀតនេះ សម្ដេចរដ្ឋសភាធិបតី បានប្រើពេលវេលាយ៉ាងអស់លទ្ធភាព បើទោះជាមានពេលតិចក្ដី ដើម្បីជួបប្រធានសភា និងថ្នាក់ដឹកនាំនៃបណ្ដាប្រទេសផ្សេងៗ ដែលក្នុងនោះរួមមាន បារាំង ឥណ្ឌូនេស៊ី អាល្លឺម៉ង់ ប៊ែលហ្សិក កាណាដា ម៉ិចស៊ិកូ ជាដើម ក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ក៏ដូចជាដើម្បីទាក់ទាញបណ្ដាអ្នកវិនិយោគ និងអ្នកទេសចរឱ្យមកកម្ពុជាកាន់តែច្រើនឡើង។

គ្រប់ជំនួបទាំងនេះ ភាគីជាមិត្តបានវាយតម្លៃខ្ពស់ចំពោះភាពដ៏សកម្មរបស់កម្ពុជាទាំងរាជរដ្ឋាភិបាល និងរដ្ឋសភា នៅក្នុងវេទិកាអន្តរជាតិនានា ដោយបានចែករំលែកនូវទស្សនទាននិងបទពិសោធន៍ល្អៗជាច្រើន ជួយដល់ការលើកកម្ពស់គោលការណ៍ពហុនិយម និងកិច្ចការពារសុខសន្តិភាពជូនប្រជាជាតិក្នុងតំបន់និងសកលលោក។

ដោយឡែក កិច្ចប្រជុំកំពូលប្រធានសភាជាស្ត្រី ដែលមានវត្តមានប្រធានសភាស្ត្រី ចំនួន ២៥ប្រទេស មកពីទ្វីបផ្សេងៗគ្នាក្នុងសកលលោកចូលរួម គឺជាមោទកភាពរបស់កម្ពុជា និងជាឱកាសរដ្ឋសភាកម្ពុជាលើកកម្ពស់វិស័យការទូតសភា ជាមួយសភានានាទាំងក្នុងតំបន់និងពិភពលោក ក្នុងការជំរុញយន្តការសភាដើម្បីដោះស្រាយនិងស្វែងរកផលប្រយោជន៍ជូនប្រជាពលរដ្ឋ ជាពិសេស«ស្ត្រីនិងកុមារី»។ តាមរយៈការពង្រឹងវិស័យការទូតសភា យើងបានរឹតចំណងមិត្តភាព និងសហប្រតិបត្តិការកាន់តែសកម្មជាមួយសមភាគីបារាំង និងសភាបណ្ដាប្រទេសនានា ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំកំពូលនោះ ដូចជាការទាក់ទាញអ្នកវិនិយោគ អ្នកទេសចរ ស្វែងរកគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស ការអប់រំ ជំនួយវិស័យសុខាភិបាល ការអភិរក្ស និងអភិវឌ្ឍវិស័យវប្បធម៌ ការពង្រឹងសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ការភ្ជាប់ទំនាក់ទំនងរដ្ឋសភាកម្ពុជាជាមួយរដ្ឋសភានានានៅគ្រប់កម្រិត ទាំងកម្រិតថ្នាក់ដឹកនាំ គណៈកម្មការជំនាញ តំណាងរាស្ត្រ តំណាងរាស្ត្រជាស្ត្រី តំណាងរាស្ត្រវ័យក្មេង និងកម្រិតអគ្គលេខាធិការដ្ឋានរដ្ឋសភាផងដែរ។

*ទូលបង្គំ ខ្ញុំ **កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** ប្រធានរដ្ឋសភាស្ដីទី និងជាតំណាងដ៏ខ្ពង់ខ្ពស់**សម្ដេចរដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** ទូលបង្គំ ខ្ញុំ បាន៖

○ ទទួលជួបពិភាក្សាការងារជាមួយ**លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រ** (Paetongtarn Shinawatra) ប្រធានគណបក្សភឿថៃ និង

○ ទទួលបដិសណ្ឋារកិច្ច ទទួលជួបសវនាការ និងពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តម វ៉ាន់មូហាម៉ាត់ណា មះថា** (Wanmuhamadnoor Matha) ប្រធានរដ្ឋសភានិងជាប្រធានសភាតំណាងរាស្ត្រនៃព្រះរាជាណាចក្រថៃ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋសភាប្រទេសទាំងពីរឱ្យកាន់តែសកម្ម និងគ្រប់ជ្រុងជ្រោយទាំងក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ក៏ដូចជាការពង្រឹងពង្រីកទំនាក់ទំនង ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាប្រពៃណីនៃប្រទេសទាំងពីរឱ្យបានឈានដល់ **«ភាពជាដៃគូយុទ្ធសាស្ត្រ»** នៅក្នុងការបម្រើផលប្រយោជន៍ប្រជាជននៃប្រទេសទាំងសងខាង។

○ អនុញ្ញាតឱ្យគណៈប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដឹកនាំដោយ **ឯកឧត្តម ខាំចាញ់ សុផាប៉ាសឺត** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការកិច្ចការជនជាតិភាគតិច និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

○ អនុញ្ញាតឱ្យគណៈប្រតិភូសភានៃសហព័ន្ធអាល្លឺម៉ង់ ដឹកនាំដោយឯកឧត្តម Tino CHRUPALLA ប្រធានក្រុមសភានៃគណបក្ស AfD នៃសហព័ន្ធអាល្លឺម៉ង់ និងសហការី ជួបសវនាការ និងពិភាក្សាការងារ។

  ○ អនុញ្ញាតឱ្យគណៈប្រតិភូនៃគណៈកម្មាធិការសម្របសម្រួលញត្តិ (Petitions Committee) នៃរដ្ឋសភាអាល្លឺម៉ង់ ដឹកនាំដោយលោកជំទាវ ម៉ាទីណា ស្តាម ហ្វីប៊ីជ Martina Stamm-Flbich (គណបក្សប្រជាធិប និងសហការី ចូលជួបសម្តែងការគួសម និងពិភាក្សាការងារ)។

*ក្រៅពីនេះ មានសកម្មភាពផ្សេងៗទៀតទាក់ទងនឹងការងារការទូតសភាដែលយើងបានបំពេញ ដូចជា៖

○ រដ្ឋសភាកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពី "ទំនាក់ទំនងកម្ពុជានិងអឺរ៉ុប ក្នុងការតភ្ជាប់តំបន់និងសន្តិភាព" ក្នុងគោលបំណងចែករំលែកព័ត៌មានអំពីសមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាពនៃទំនាក់ទំនងរវាងកម្ពុជានិងសហភាពអឺរ៉ុប ទាំងក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល និងរដ្ឋសភា។

○ ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី បានទទួលនិងចូលរួមក្នុងសវនាការសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកអគ្គរាជទូត ភ្ញៀវជាតិអន្តរជាតិនិងអង្គការអន្តរជាតិនានា និងបានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា(IPU) និងកិច្ចប្រជុំវេទិកាស្ត្រីនៃមហាសន្និបាតអាយភីយូលើកទី១៤៨ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

## II-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំរដ្ឋសភា

ក្រៅពីចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ និងការងារការទូតខាងលើ **សម្តេចមហាររដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ ឯកឧត្តម **វង សូត** អនុប្រធានទី២ បានបំពេញការងារមួយចំនួនទៀត ដែលមានដូចតទៅ៖

ក-សកម្មភាពការងាររបស់សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា

នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧ **សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា** បានបំពេញការងារផ្សេងៗទៀតទាក់ទងនឹងការងារសង្គមដែលក្នុងនោះមាន ការចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងការចូលរួមកម្មវិធីផ្សេងៗ មានជាអាទិ៍ៈ

- បានចូលរួមដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងទៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។
- បានដឹកនាំគណៈប្រតិភូរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាគោរពវិញ្ញាណក្ខន្ធ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា។
- បានចូលរួមជាគណៈអធិបតីក្នុងពិធីសំណេះសំណាលជាមួយអង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ (មណ្ឌលរាជធានីភ្នំពេញ និងខេត្តកណ្តាល) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា នៅវិមាន៧មករា។
- បានជួបប្រជុំពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម ប្រាក់ សុខុន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
- បានចូលរួមជាគណៈអធិបតីក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៤៥នៃទិវាជ័យជម្នះ៧មករា នៅទីធ្លាមុខសាលមហោស្រពកោះពេជ្រ។
- បានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរក្នុងឱកាសនៃព្រះរាជពិធីចម្រើនព្រះជន្ម **ព្រះចៅអធិរាជជប៉ុន ណារុហ៊ីតុ (NARUHITO)** ។
- បានចូលរួមជាភ្ញៀវកែស្សរជនជាន់ខ្ពស់ក្នុងពិធីពិសាភោជនាហារស្និទ្ធស្នាលរវាងស្ថានទូតវៀតណាម និងគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា នៅស្ថានទូតវៀតណាម។
- បានចូលរួមជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណៈបក្សប្រជាជនកម្ពុជា។
- បានចូលរួមបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នៅការិយាល័យបោះឆ្នោត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល។
- បានចូលរួមជាអធិបតី ក្នុងពិធីបុណ្យមាឃបូជា នៅភ្នំព្រះរាជទ្រព្យ ( ឧត្តុង្គ ) ខេត្តកណ្តាល។
- បានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរខួបគម្រប់១៥ឆ្នាំរបស់ក្រុមហ៊ុនទូរគមនាគមន៍មិត្តហ្វូន (Metfone) ។
- បានចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងមុខតំណែងរបស់គណបក្សប្រជាជនកម្ពុជាឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ ។
- បានដឹកនាំកិច្ចប្រជុំគណៈកម្មការចំពោះកិច្ចដើម្បីពិនិត្យតាមដានអំពីវឌ្ឍនភាពនិងលទ្ធផល នៃគម្រោងសាងសង់អគាររដ្ឋបាលថ្មី នៃរដ្ឋសភា ចំនួន ២ លើក។
- បានចូលរួមជាអធិបតី ពិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ «ស្ត្រីនិងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល» ដែលមានគោលបំណងលើកកម្ពស់ការយល់ដឹង និងការយកចិត្តទុកដាក់ខ្ពស់ចំពោះ «ស្ត្រីនិងក្មេងស្រី» ក្នុងការចូលរួមក្នុងបរិវត្តកម្មឌីជីថល ស្របតាមការរីកចម្រើន

ឥតឈប់ឈរនៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល នៅខេត្តកណ្តាល ដោយមានអ្នកចូលរួមជាង ២០០០នាក់។

**ខ-សកម្មភាពការងាររបស់ទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ រដ្ឋសភា**

ទូលបង្គំ ខ្ញុំ បានបំពេញការងារមួយចំនួន ការចុះមូលដ្ឋានដើម្បីសួរសុខទុក្ខប្រជាពលរដ្ឋ និងចូលរួមពិធីសម្ពោធសមិទ្ធផលផ្សេងៗ មានជាអាទិ៍៖

- បានបំពេញតួនាទីជាប្រធានស្តីទីរដ្ឋសភាចំនួនពីរលើក ដោយបាន៖
  - អញ្ជើញជាអធិបតីភាព ក្នុងពិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ " ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល "។
  - ជួបសំណេះសំណាលជាមួយក្រុមសភាជាតិកម្ពុជា នៃអ្នកនយោបាយសភាស្ត្រី ដឹកនាំដោយលោកជំទាវ និន សាផុន នៅក្នុងឱកាសពិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ " ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល "។
- បានចុះពិនិត្យមើលវឌ្ឍនភាពការកសាងសង់អគារសិក្សានៅអនុវិទ្យាល័យបន្លិចប្រាសាទស្ថិតនៅឃុំបន្លិចប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង។
- បានជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងស្រុកព្រះស្តេចចំនួន៧៥រូប។
- បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធអគារសិក្សា១ខ្នង កម្ពស់២ជាន់ មាន១០បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាប្រុបុសរលួយ ក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង។
- បានចូលរួមនិងដឹកនាំកិច្ចប្រជុំនានាចំនួន **៣លើក** ដូចជា៖ ១-ដឹកនាំកិច្ចប្រជុំជាមួយតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងទិសដៅបន្ត ២-ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយតួនាទី ភារកិច្ច និងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមរដ្ឋសភាកម្ពុជានៃស្ថាប័នអន្តរសភាអាស៊ាន (AIPA) និង ៣-ដឹកនាំកិច្ចប្រជុំត្រៀមបើកការដ្ឋានសាងសង់ផ្លូវលំមួយខ្សែប្រវែងជាង២គីឡូម៉ែត្រ នៅស្រុកពាមរក៍ ខេត្តព្រៃវែង។
- បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីមីទ្ទីញអបអរសាទរខួបលើកទី៤៥ នៃទិវាបុណ្យជាតិជ័យជម្នះ(៧មករា ១៩៧៩ - ៧មករា ២០២៤) ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ នៃស្រុកពាមរក៍ ស្រុកព្រះស្តេច និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
- បានអនុញ្ញាតឱ្យឯក**ឧត្តមបណ្ឌិត លី ឆេង និងឯកឧត្តម សន សាណា** ព្រមទាំងមន្ត្រីមួយចំនួនដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំក្រុមការងារ (Tasks Force) ស្តីពីការបង្កើតបណ្ណាល័យច្បាប់ឌីជីថល (Digital Law Library) និងពង្រឹងគោលការណ៍ណែនាំ នៃការចូលរួមរបស់អាយប៉ាជាមួយភាគីខាងក្រៅ។
- បានអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី២៥ ថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ (២៤ មករា ១៩៩៩ - ២៤ មករា ២០២៤) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ នៅខេត្តព្រៃវែង។

គ -ឯកឧត្តម វង សូត អនុប្រធានទី២ រដ្ឋសភា

ឯកឧត្តមអនុប្រធានទី២ រដ្ឋសភា បានចូលរួមកម្មវិធីនានា មានជាអាទិ៍៖

- បានចូលរួមជាអធិបតីក្នុងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានានៅវត្តបុទុម្ពរ ហៅវត្តសៀមបោយ,
- បានចូលរួមពិធីលើកតម្កល់រតនៈវត្ថុ ចំនួន៩អង្គ នៅវត្តសាមគ្គីសុខារាម ហៅវត្តច្រេងរំដេង នៅភូមិច្រេងរំដេង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ,
- បានចូលរួមជាអធិបតីក្នុងពិធីអបអរសាទរខួបទី៤៥ ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ៧ មករា នៅបរិវេណសាលាស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងនៅកោះពេជ្រ,
- បានចូលរួមជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងខេត្តត្បូងឃ្មុំ,
- បានចូលរួមពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី២៥ថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី
- បានចូលរួមបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ នៅខេត្តត្បូងឃ្មុំ។
- បានចូលរួមប្រជុំគណៈកម្មការគ្រប់គ្រងការសាងសង់អគាររដ្ឋបាលថ្មីនៃរដ្ឋសភា។

## III-**សកម្មភាពការងាររបស់គណៈកម្មការនានានៃរដ្ឋសភា**

នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧នេះ គណៈកម្មការនានានៃរដ្ឋសភា បានបំពេញការងារសំខាន់ៗតាមតួនាទីនិងភារកិច្ច ដូចមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងសេចក្តីសម្រេចរបស់រដ្ឋសភា ដោយសម្រេចបានលទ្ធផលដូចតទៅ៖

### ក-សកម្មភាពការងារនីតិកម្ម

១- គណៈកម្មការនានានៃរដ្ឋសភាបានប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន២ គឺ៖

- គណៈកម្មការទី៥ សហការជាមួយគណៈកម្មការទី៩ និងគណៈកម្មការទី៣ ដោយមានការចូលរួមពីតំណាងគណៈកម្មការនានានៃរដ្ឋសភា បានប្រជុំជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសិក្សាសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល។
- គណៈកម្មការទី៩ និងតំណាងគណៈកម្មការនានានៃរដ្ឋសភា បានប្រជុំជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងជាតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាសេចក្តីព្រាងច្បាប់ស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក។

២-គណៈកម្មការនានានៃរដ្ឋសភាបានប្រជុំពិនិត្យនិងផ្តល់យោបល់លើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការងារនីតិកម្ម មានដូចតទៅ៖

- សមាជិក សមាជិការដ្ឋសភាបានពិនិត្យ សិក្សា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីភូមិបាល តាមសេចក្តីស្នើសុំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- គណៈកម្មការទី២ បានអញ្ជើញមន្ត្រីជំនាញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យនិងពិភាក្សាលើការឆ្លើយកម្រងសំណួរនៃការអង្កេតលើការបើកចំហថវិកា តាមសេចក្តីស្នើសុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ គណៈកម្មការបានប្រគល់ភារកិច្ចជូនមន្ត្រីជំនាញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សហការធ្វើការរៀបចំចម្លើយនៃកម្រងសំណួរផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តិនានារបស់ព្រះរាជាណាចក្រកម្ពុជា ហើយធ្វើរបាយការណ៍ជូនគណៈកម្មការទី២ ដើម្បីពិនិត្យ និងសម្រេច។

ខ-សកម្មភាពការងារតាមដានការអនុវត្តច្បាប់

១- សកម្មភាពការអញ្ជើញក្រសួង និងស្ថាប័ននានា មកបំភ្លឺ

គណៈកម្មការនានានៃរដ្ឋសភាបានអញ្ជើញតំណាងរាជរដ្ឋាភិបាលជាឥស្សរជនថ្នាក់ដឹកនាំក្រសួង ស្ថាប័ននានា ចំណុះរាជរដ្ឋាភិបាលបានចំនួន ១៩លើក ក្នុងនោះមាន៖

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងនិងអង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា **ចំនួន ១លើក**
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម **ចំនួន ៤លើក**
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន **ចំនួន ២លើក**
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌ **ចំនួន ១លើក**
- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ **ចំនួន ៤លើក**
- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី **ចំនួន ៤លើក**
- គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **ចំនួន ៣លើក**។

ក្នុងការជួបប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលជាឥស្សរជនថ្នាក់ដឹកនាំក្រសួង ស្ថាប័ន គណៈកម្មការជំនាញ និងតំណាងគណៈកម្មការនានានៃរដ្ឋសភា បានស្វែងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅអនុវត្តការងាររបស់ក្រសួង ក្នុងវិស័យទទួលខុសត្រូវរបស់ខ្លួន ដូចជា ការងារអភិបាលកិច្ចល្អ វិស័យកសិកម្ម បច្ចេកទេសដាំដុះ ប្រព័ន្ធធារាសាស្ត្រ ការពង្រឹងទីផ្សារកសិផល វិស័យអប់រំ ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រប់កម្រិត ការបណ្តុះបណ្តាលជំនាញបច្ចេកទេស វិស័យអគ្គិសនីមានថាមពលកកើតឡើងវិញ ប្រព័ន្ធគាំពារសង្គម វិស័យយុត្តិធម៌ដែលមានកិច្ចការជាអាទិភាពចំនួន ៣ រួមមាន ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាជន, និងការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ព្រមទាំងដាក់ចេញវិធានការម៉ឺងម៉ាត់ជាដាច់ខាតជម្រុញដោះស្រាយសម្រាប់សំណុំរឿងគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ និងសំណុំរឿងពាក់ព័ន្ធនឹងអគ្រានុកូលដ្ឋាន ដើម្បីលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវ នៅក្នុងការអនុវត្តច្បាប់និងចំណាត់ការរឿងក្តីដោយតុលាការជាដើម។

ជាមួយគ្នានេះ គណៈកម្មការជំនាញរដ្ឋសភាបានសំណូមពរនិងលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន ត្រូវខិតខំបន្តពង្រឹងការអនុវត្តតួនាទីរបស់ខ្លួនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដោយកំណត់យកអាទិភាពគន្លឹះចំនួន ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**។

**២-សកម្មភាពការងារបំពេញបេសកកម្មតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត**

គណៈកម្មការនានានៃរដ្ឋសភាបានចុះបំពេញបេសកកម្មនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីសិក្សាស្វែងយល់អំពីបញ្ហាដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ ចំនួន ១៤ លើក មានដូចតទៅ៖

- **គណៈកម្មការទី១** បានបំពេញបេសកកម្មនៅខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដោយបានស្វែងយល់អំពីវឌ្ឍនភាពការងារ និងយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដែលមានលទ្ធផលដូចតទៅ៖
    - អាជ្ញាធរខេត្តទាំង៤ បានធ្វើការអភិវឌ្ឍជាជំហានៗ និងឆ្ពោះទៅកាន់ការអភិវឌ្ឍដ៏ឆាប់រហ័សក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងក្របខណ្ឌយុទ្ធសាស្ត្ររបស់ខេត្ត ដែលជាប្រភពធនធានមានសក្តានុពលសម្រាប់វិនិយោគ និងអភិវឌ្ឍលើវិស័យទេសចរណ៍ ដើម្បីជាប្រយោជន៍សេដ្ឋកិច្ចជូនប្រជាពលរដ្ឋនៅខេត្តទាំង៤។
    - អាជ្ញាធរខេត្តទាំង៤ បានដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋតាមយន្តការក្រៅប្រព័ន្ធតុលាការ និងសហការជាមួយនឹងក្រុមការងារថ្នាក់ជាតិ ដែលមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នូវករណីពាក្យបណ្តឹងវិវាទដីធ្លីមិនទាន់មានប័ណ្ណកម្មសិទ្ធិ ។
    - អាជ្ញាធរខេត្តទាំង៤ មានការិយាល័យប្រជាពលរដ្ឋ ដែលមានតួនាទី និងភារកិច្ចទទួលពាក្យបណ្តឹងនិងដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
    - អាជ្ញាធរខេត្តទាំង៤ បានទទួលយកលិខិតសំណើសុំដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋរបស់គណៈកម្មការទី១ នៃរដ្ឋសភា ដើម្បីពិនិត្យស្រាវជ្រាវនិងដោះស្រាយតាមនីតិវិធី និងច្បាប់ជាធរមាន និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភាវិញ។
    - គណៈកម្មការ បានផ្តល់អនុសាសន៍មួយចំនួនដល់អាជ្ញាធរខេត្តទាំង៤ ឱ្យបន្តការខិតខំដោះស្រាយលើបណ្តឹងផ្សេងៗរបស់ប្រជាពលរដ្ឋដែលមិនទាន់ដោះស្រាយចប់ជាស្ថាពរ ពិសេសយកចិត្តទុកដាក់ដោះស្រាយពាក្យបណ្តឹងទំនាស់ដីធ្លីឱ្យបានទាន់ពេលវេលា។

-**គណៈកម្មការទី២** បានចូលរួមក្នុងកិច្ចពិភាក្សាស្តីពី "**ការគ្រប់គ្រងល្បែងផ្សងសំណាង និងការគ្រប់គ្រងផលប៉ះពាល់ពីល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ**" សំដៅលើកកម្ពស់ការយល់ដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងចាត់វិធានការបង្ក្រាបនិងទប់ស្កាត់រាល់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ដើម្បីលុបបំបាត់ផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤។

ការគ្រប់គ្រងល្បែងផ្សងសំណាងនេះ ផ្អែកទៅលើច្បាប់គោលចំនួន២ គឺច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង ព្រមជាមួយសេចក្តីណែនាំអន្តរក្រសួង និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។ កិច្ចពិភាក្សានេះត្រូវបានធ្វើនៅខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដែលមានសមាសភាពអញ្ជើញចូលរួមមកពីគណៈកម្មការទី២ នៃរដ្ឋសភា គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរនានា កងកម្លាំងប្រដាប់អាវុធ និងតំណាងប្រតិបត្តិករល្បែងផ្សងសំណាង សរុបប្រមាណ១៥៦០នាក់ ព្រមទាំងក្រុមហ៊ុនល្បែងផ្សងសំណាង ដែលមានអាជ្ញាប័ណ្ណសរុបចំនួន១៦សាខា ដោយមានលទ្ធផលជារួមដូចតទៅ ៖

- ទីតាំងល្បែងផ្សងសំណាងខុសច្បាប់សរុបចំនួន ២២៨៨ទីតាំង ត្រូវបានបិទជាស្ថាពរ។
- កិច្ចពិភាក្សាពិនិត្យឃើញថា ទាំងអាជ្ញាធរមានសមត្ថកិច្ច ប្រតិបត្តិករល្បែងផ្សងសំណាង និងអ្នកចូលរួមពុំទាន់យល់ច្បាស់លើលក្ខខណ្ឌកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងល្បែងពាណិជ្ជកម្មនៅឡើយទេ ម្យ៉ាងទៀតការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងល្បែងពាណិជ្ជកម្មដល់អាជ្ញាធរមានសមត្ថកិច្ចនិងសាធារណជនក៏នៅមានកម្រិត តែក្រោយពីបានផ្លាស់ប្តូរយោបល់ ពិភាក្សាយ៉ាងផុលផុសរួចមកឃើញថា មានការយល់ដឹងច្រើន។ អាស្រ័យហេតុនេះ ដើម្បីពង្រឹងការគ្រប់គ្រងល្បែងផ្សងសំណាង និងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានពីល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គណៈកម្មការទី២ និងគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា នឹងបន្តចុះធ្វើការផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ច និងសាធារណជនឱ្យបានយល់ដឹងកាន់តែច្បាស់អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា តាមបណ្តាខេត្តផ្សេងៗទៀត ដូចជា ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់នាពេលខាងមុខ។

តាមការណែនាំរបស់**សម្តេចក្រឡាហោម ស ខេង** តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មការទី២ សហការជាមួយអាជ្ញាធរខេត្តបានចុះដោះស្រាយបញ្ហាខ្វះទឹកជូនប្រជាកសិករសម្រាប់ធ្វើស្រែប្រាំង។ បញ្ហាខ្វះទឹកនៅក្នុងរដូវប្រាំងនេះ គឺបណ្តាលមកពីប្រជាកសិករបានបង្កើនការធ្វើស្រែប្រាំងរហូត ៣ ទៅ ៤ដង ដើម្បីឆ្លើយតបទៅនឹងតម្លៃស្រូវកំពុងមានការកើនឡើង។

- **គណៈកម្មការទី៣** បានបំពេញបេសកកម្មនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ដើម្បីសិក្សាឈ្វេងយល់អំពីការអភិវឌ្ឍ បញ្ហាប្រឈមនានារបស់រដ្ឋបាលខេត្ត និងមន្ទីរអង្គភាពជំនាញ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការ ដែលមានលទ្ធផលដូចតទៅ៖
  - ការអនុវត្តច្បាប់របស់អាជ្ញាខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធទាំងពីរខេត្ត មានការរីកចំរើនគួរជាទីកត់សម្គាល់ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។
  - បានចុះសិក្សាស្វែងយល់អំពីស្ថានភាពប្រជាពលរដ្ឋ និងជួបសំណេះសំណាលជាមួយសហគមន៍បន្លែសុវត្ថិភាព ។

- បានចុះពិនិត្យប្រព័ន្ធធារាសាស្ត្រ ទំនប់សេកសក ទំនប់ចារឹត ខេត្តបាត់ដំបង ទំនប់ដំណាក់ឈើក្រម ទំនប់ដំណាក់អំពិល និងទំនប់ក្បាលហុង ខេត្តពោធិ៍សាត់។

- **គណៈកម្មការទី៤ និងគណៈកម្មការទី៥** បានបំពេញបេសកកម្មនៅបណ្តាខេត្តនានាជាប់ព្រំដែនប្រទេសថៃ ដើម្បីសិក្សាស្វែងយល់អំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកម្លាំងការពារព្រំដែន ព្រមទាំងជួបប្រជុំពិភាក្សាការងារទ្វេភាគីជាមួយសមភាគីថៃ(គណៈកម្មការរដ្ឋសភាថៃ)ដើម្បីស្វែងយល់អំពីកិច្ចសហប្រតិបត្តិការទ្វេភាគី លើផ្នែកសហប្រតិបត្តិការអន្តរជាតិ ការពារជាតិ និងសន្តិសុខ នៅតាមបណ្តោយព្រំដែន ដែលមានលទ្ធផលសំខាន់ៗដូចតទៅៈ
  - ជួបប្រជុំជាមួយតំណាងអាជ្ញាធរខេត្តទាំង៦ រួមមានខេត្ត បន្ទាយមានជ័យ កោះកុង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន ព្រះវិហារ និងតំណាងក្រសួង-ស្ថាប័នចំនួន៧ រួមមាន តំណាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន និងតំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។
  - បានស្វែងយល់អំពីស្ថានភាពប្រជាពលរដ្ឋ ការងារសហប្រតិបត្តិការអន្តរជាតិ បញ្ហាឆ្លងដែន ការងារសន្តិសុខជាតិ និងព័ត៌មានផ្សេងៗ នៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសថៃ។
  - បានជួបសំណេះសំណាលជាមួយកងកម្លាំងជួរមុខការពារព្រំដែនទិសប្រាសាទតាមាន់-តាក្របី នៅទីបញ្ជាការវរសេនាតូចលេខ៤២២ និងបានពាំនាំនូវអំណោយដ៏ថ្លៃថ្លារបស់**សម្តេចរដ្ឋសភាធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** ប្រគល់ជូនដល់អង្គភាពចំនួន៤ រួមមានៈ កងពលតូចថ្មើរជើងលេខ ៤២ វរៈសេនាតូចលេខ ៤២២ ប្រតិបត្តិការសឹករងខេត្តឧត្តរមានជ័យ (វរៈការពារព្រំដែន) និងវរៈការពារព្រំដែនគោក ៧០២។
  - បានទស្សនាប្រាសាទតាមាន់ ទស្សនាប្រាសាទបន្ទាយឆ្មារ ទស្សនារោងចក្រដំឡើងរថយន្ត KIA និងទស្សនាច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់។

- **គណៈកម្មការទី៦** បានបំពេញបេសកកម្មនៅខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ដើម្បីជួបពិភាក្សាការងារ និងឈ្វេងយល់អំពីការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌ និងជួបប្រជុំពិភាក្សាជាមួយអាជ្ញាធរខេត្ត ប្រធានសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត និងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង ទទួលបានលទ្ធផលដូចខាងក្រោមៈ
  - ការអនុវត្តច្បាប់របស់អាជ្ញាធរខេត្ត សាលាដំបូងខេត្ត សាលាឧទ្ធរណ៍តំបន់បាត់ដំបងបានល្អប្រសើរ ទោះបីនៅមានការខ្វះចន្លោះខ្លះៗក្តី។
  - សាលាដំបូងខេត្ត បានជម្រុញដោះស្រាយសំណុំរឿងបានឆាប់រហ័ស ពិសេសសំណុំរឿងពាក់ព័ន្ធនឹងគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ និងការសុំកែសំបុត្រអត្រានុកូលដ្ឋាន ។
  - សាលាដំបូងខេត្ត នៅមានការខ្វះមធ្យោបាយ សម្ភារៈមួយចំនួនសម្រាប់បម្រើឱ្យការអនុវត្តវិស័យយុត្តិធម៌ និងកង្វះចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលមួយចំនួនទៀត។

- ប្រជាពលរដ្ឋ និងមន្ត្រីអនុវត្តច្បាប់មួយចំនួន មានការយល់ដឹងអំពីច្បាប់នៅមានកម្រិត ដើម្បីធានាបានប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ លើកកំពស់អភិបាលកិច្ចល្អ និងការពង្រឹងនីតិរដ្ឋ ក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ចាំបាច់ត្រូវផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ដល់អាជ្ញាធរមូលដ្ឋាន មន្ត្រីអនុវត្តច្បាប់ និងប្រជាពលរដ្ឋ។
- គណៈកម្មការបានផ្តល់អនុសាសន៍មួយចំនួនដល់អាជ្ញាធរខេត្ត និងអង្គភាពជំនាញ សហការជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូងឱ្យបានល្អក្នុងការដោះស្រាយពាក្យបណ្តឹង និងសំណូមពររបស់ប្រជាពលរដ្ឋ និងការបង្ក្រាបរាល់បទល្មើសដែលកើតមានឡើងប្រកបដោយប្រសិទ្ធភាព។

- **គណៈកម្មការទី៧** បានចុះបេសកកម្ម ទៅខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ដើម្បីក្តាប់សភាពការណ៍ទូទៅរបស់ខេត្តពាក់ព័ន្ធនឹងវិស័យដែលគណៈកម្មការទទួលខុសត្រូវ ដោយបានស្វែងយល់ជារួមអំពីសភាពការណ៍ទូទៅនៅក្នុងខេត្ត វិស័យទាំងបួនរួមមាន អប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ ព្រមទាំងបានស្វែងយល់បន្ថែមនូវចំណុចវិជ្ជមាន អវិជ្ជមាន និងចំណុចខ្វះខាតមួយចំនួនក្នុងការអនុវត្តគោលនយោបាយបញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ក្នុងន័យនេះ ដើម្បីចូលរួមលើកកម្ពស់វិស័យទាំងបួនឱ្យកាន់តែរីកចម្រើន គណៈកម្មការនឹងបន្តធ្វើការជាមួយក្រសួងពាក់ព័ន្ធ តាមរយៈកិច្ចពិភាក្សា និងការផ្តល់ព័ត៌មានទាំងនោះជូនក្រសួងក្នុងការធ្វើការវាយតម្លៃ និងមានវិធានការផ្សេងៗលើការអនុវត្តគោលនយោបាយរបស់ខ្លួន។ ជាមួយគ្នានេះដែរ គណៈកម្មការបានស្នើសុំអាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធសូមសហការគ្នាទៅវិញទៅមក ដើម្បីប្រតិបត្តិការងារនៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព និងបានស្នើឱ្យខេត្តនិងមន្ទីរអង្គភាពជំនាញវាយតម្លៃការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងបង្កើនភាពច្នៃប្រឌិតចេញពីបទពិសោធន៍ និងស្ថានភាពជាក់ស្តែង ដោយលើកឡើងនូវបញ្ហាប្រឈម ដំណោះស្រាយ និងផែនការទិសដៅការងារ ដើម្បីឈានទៅរកការអភិវឌ្ឍនៅក្នុងខេត្តនីមួយៗ ឱ្យកាន់តែប្រសើរមួយកម្រិតទៀត ជាជាងរង់ចាំតែការដាក់គោលនយោបាយពីថ្នាក់ជាតិមកវិញ ដែលមិនសូវសមស្របទៅតាមភូមិសាស្ត្រខុសប្លែកគ្នានៅទូទាំងប្រទេស។

- **គណៈកម្មការទី៨** បានបំពេញបេសកកម្មនៅរាជធានីភ្នំពេញ ខេត្តកណ្តាលខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីពិភាក្សាការងារជាមួយរដ្ឋបាលរាជធានី-ខេត្ត មន្ទីរជំនាញ មជ្ឈមណ្ឌលកុមារកំព្រា មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងវិទ្យាស្ថានពហុបច្ចេកទេសនានា រោងចក្រកាត់ដេរ និងពិនិត្យនិងស្វែងយល់វិស័យកសិឧស្សាហកម្ម ដែលមានលទ្ធផលដូចតទៅ៖
  - **វិស័យសុខាភិបាល៖**
    - ថ្នាក់ដឹកនាំខេត្ត និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត បានយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញដោយក្រសួងសុខាភិបាល ក្នុងការផ្តល់សេវាថែទាំសុខភាពនៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងឃើញថាមានលក្ខណៈល្អប្រសើរ រួមទាំងការផ្តល់សេវាដល់សមាជិក ប.ស.ស និងមូលនិធិសមធម៌។

- បញ្ហាប្រឈមរបស់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព មានការខ្វះខាតឱសថ និងសម្ភារ បរិក្ខារ សុខាភិបាលមួយចំនួន សម្រាប់ប្រើប្រាស់ប្រចាំខែឬប្រចាំឆ្នាំ។
- ក្រុមគ្រូពេទ្យបានទទួលការបណ្ដុះបណ្ដាលចំណេះជំនាញបន្ថែមពីឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពង្រឹង សមត្ថភាព និងគុណភាពនៃការផ្ដល់សេវាឱ្យបានទាន់ពេលវេលា តាមរយៈប្រព័ន្ធនិម្មិត។

○ **វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅបណ្ដារាជធានី ខេត្ត បានអនុវត្ត៖**

- គោលនយោបាយរបស់រាជរដ្ឋាភិបាលស្ដីពី កម្មវិធីឧបត្ថម្ភ ៖ ១-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ដ្រី ក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ២-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ៣-កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាពគ្រួសារមានអ្នកឆ្លងជំងឺកូវីដ- ១៩ និងគ្រួសារមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង៤-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារ ងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា។
- បានត្រៀមអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលនឹងអនុវត្តនៅខែមេសា ឆ្នាំ២០២៤ មានកម្មវិធីចំនួន៤ នឹងត្រូវធ្វើសមាហរណកម្មខងារក្រោមកញ្ចប់គ្រួសារ រួមមាន ១-កម្មវិធីឧបត្ថម្ភ សាច់ប្រាក់ជូនស្ដ្រីក្រីក្រមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ ២-កម្មវិធីអាហារូបករណ៍សម្រាប់ សិស្សក្រីក្រថ្នាក់បឋមសិក្សានិងមធ្យមសិក្សា ៣-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និង៤-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឆ្នាំឡើង)។

○ **វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅបណ្ដារាជធានី ខេត្ត បានអនុវត្ត៖**

- កម្មវិធីបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ។
- គោលនយោបាយរបបសន្តិសុខសង្គម គឺ សមាជិក ប.ស.ស អ្នកសេដ្ឋកិច្ចក្នុងប្រព័ន្ធ មានការ យល់ដឹងច្រើន អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប័ណ្ណ ប.ស.ស និងទៅទទួលយកសេវាថែទាំ សុខភាពនៅតាមមូលដ្ឋានសុខាភិបាល មានការកើនឡើងពីមួយខែទៅមួយខែ។ ដោយឡែក បុគ្គលស្វ័យនិយោជន៍ និងសហព័ទ្ធ មានការពេញចិត្ត និងចូលរួមក្នុងកម្មវិធីរបបសន្តិសុខ សង្គមផ្នែកថែទាំសុខភាព តាមរបបភាគទាន ដោយស្ម័គ្រចិត្តសម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ព្រោះកម្មវិធីមួយនេះ បានជួយសម្រាលបន្ទុកចំណាយផ្នែកថែទាំសុខភាពដល់ សមាជិក ប.ស.ស ដែលជាបុគ្គលស្វ័យនិយោជន៍ និងក្រុមគ្រួសារបានច្រើន។
- ចំពោះការទូទាត់របស់ ប.ស.ស ជាមួយមូលដ្ឋានសុខាភិបាល ឃើញថាមានដំណើរការវិវឌ្ឍ ល្អប្រសើរ និងទាន់ពេលវេលា ប៉ុន្តែនៅមានជួបបញ្ហាតិចតួចមួយចំនួន ដោយសារប្រព័ន្ធអ៊ីន ធឺណេតខ្សោយ និងការខុសឯកសារជាដើម។

○ **វិស័យកិច្ចការនារី នៅបណ្ដារាជធានី ខេត្ត បានអនុវត្តសកម្មភាពការងារវិស័យកិច្ចការនារី**

- ថ្វីត្បិតការអនុវត្តសកម្មភាពនៅមានជួបប្រទះបញ្ហាប្រឈមមួយចំនួនក្ដី ទាំងថ្នាក់ដឹកនាំ និង បុគ្គលិកមន្ទីរកិច្ចការនារីរាជធានី-ខេត្ត នៅតែអាចបំពេញភារកិច្ច និងសម្រេចតាមផែនការ ប្រកបដោយជោគជ័យ ដោយសារមន្ត្រីកិច្ចការនារីមានទំនួលខុសត្រូវនិងមានឆន្ទៈខ្ពស់ក្នុងការ បំពេញការងារដោយឥតរាថយ។ ជាលទ្ធផល តាមរយៈការបញ្ជ្រាបយេនឌ័រ គោលនយោបាយ

ផែនការ និងកម្មវិធីពាក់ព័ន្ធនានារួមទាំងការអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងយ៉ាងទូលំទូលាយ ដល់ប្រជាពលរដ្ឋនៅគ្រប់ស្រទាប់វណ្ណៈ បានធ្វើឲ្យផ្នត់គំនិតសង្គមដែលធ្លាប់តែរារាំងក្មេងស្រី និងស្ត្រី ក្នុងការទទួលបានការអប់រំ ត្រូវបានលុបបំបាត់ជាបណ្តើរៗផងដែរ។

- **គណៈកម្មការទី៩** បានបំពេញបេសកកម្មនៅខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី ដើម្បីស្វែងយល់អំពីវឌ្ឍនភាពការងាររបស់រដ្ឋបាលខេត្ត និងមន្ទីរអង្គភាពជំនាញពាក់ព័ន្ធ នៃរដ្ឋបាលខេត្តទាំង៦ ទទួលបានលទ្ធផលដូចខាងក្រោម៖
  - ថ្នាក់ដឹកនាំរដ្ឋបាលខេត្ត និងមន្ទីរអង្គភាពជំនាញទាំងអស់ បានខិតខំបំពេញការងារក្នុងការអនុវត្តនូវកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។
  - គណៈកម្មការ បានផ្តល់នូវអនុសាសន៍មួយចំនួនដល់រដ្ឋបាលខេត្តទាំងបួន ដូចជា៖
    - បន្តជំរុញអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» ឱ្យមានប្រសិទ្ធភាពខ្ពស់
    - បន្តយកចិត្តទុកដាក់ផ្តល់សេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្តពីប្រជាពលរដ្ឋ។
    - បន្តធ្វើការផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយបន្ថែមទៀត។
    - សំណូមពរដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធទាំងអស់បង្កើនការយកចិត្តទុកដាក់ខ្ពស់លើការចូលរួមការពង្រឹងអភិបាលកិច្ចល្អ ប្រសិទ្ធភាព និងសមត្ថភាពស្ថាប័ន និងការលើកកម្ពស់វិស័យឯកជន កសាងធនធានមនុស្ស ផ្តល់សេវាគាំពារសង្គម និងសុខុមាលភាពប្រជាពលរដ្ឋ ពង្រឹងគុណភាពនគរូបនីយកម្មក្នុងការកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ ការពង្រឹងចីរភាពបរិស្ថានក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងជំរុញធ្វើបរិវត្តកម្មឌីជីថលទាំងក្នុងសង្គម និងសេដ្ឋកិច្ច។
  - បានចុះពិនិត្យមើលផ្ទាល់អំពីវឌ្ឍនភាពគម្រោងសាងសង់ស្តារឡើងវិញផ្លូវជាតិលេខ៤៨ ពីស្រុកស្រែអំបិល ទៅទីរួមខេត្តកោះកុង និងទស្សនកិច្ចសិក្សាស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ និងស្ទឹងឫស្សីជ្រុំខេត្តកោះកុង រោងម៉ាស៊ីនកិនស្រូវរបស់ក្រុមហ៊ុនបៃតងកម្ពុជានិងផ្សារបន្លែនៅខេត្តបាត់ដំបង រោងចក្រតម្លើងរថយន្ត Ford និងរោងចក្រផ្គុំតម្លើងគ្រង់ស្ពូរនិងខ្សែបញ្ជូនអគ្គិសនី នៅខេត្តពោធិ៍សាត់។
  - បានចុះបំពេញទស្សនកិច្ចនៅការដ្ឋានក្រុមហ៊ុនអាជីវកម្មរ៉ែមាសស្ថិតនៅភូមិចុងផ្លាស់ ឃុំអូរខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ដោយមានការធ្វើបទបង្ហាញពីវឌ្ឍនភាពការងាររបស់ក្រុមហ៊ុនរបស់លោក Morgan Hart ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រងគម្រោងអាជីវកម្មរ៉ែមាសរបស់ក្រុមហ៊ុនរ៉ឺនេសង់ មីនើរ៉ល (ខេមបូឌា) លីមីធីត (RENAISSANCE MINERALS (CAMBODIA) LIMITED) ។

នៅក្នុងការអនុវត្តមុខងារតាមដានការអនុវត្តច្បាប់នេះ ទាំងសម្តេចរដ្ឋសភាធិបតីប្រធានរដ្ឋសភា ទូលបង្គំ ខ្ញុំ កិត្តិសេដ្ឋាបណ្ឌិតអនុប្រធានទី១ និងឯកឧត្តមអនុប្រធានទី២ ព្រមទាំងសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិការដ្ឋសភាដ៏ឧត្តុង្គឧត្តមក៏បានចុះបំពេញការងារ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីស្តាប់នូវរាល់លទ្ធផលការងារនៃការអនុវត្តច្បាប់ ក៏ដូចជាសំណូមពរនិងតម្រូវការ របស់អង្គនីតិប្រតិបត្តិដែលជាអ្នកអនុវត្តច្បាប់ ដើម្បីយើងរួមគ្នាដោះស្រាយ ឆ្លើយតបតាមយន្តការរដ្ឋសភា ធ្វើយ៉ាងណាឱ្យការបម្រើប្រជាពលរដ្ឋ និងប្រទេសជាតិរបស់យើងឱ្យកាន់តែល្អប្រសើរ ឈានឆ្ពោះទៅកាន់វឌ្ឍនភាព និងវិបុលភាពជូនប្រជាពលរដ្ឋជាទីស្រលាញ់របស់យើង។

**គ-ការងារភាពជាតំណាង**

គណៈកម្មការនានានៃរដ្ឋសភាបានជួបសវនាការនិងពិភាក្សាការងារជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងគោលបំណងពង្រឹងមិត្តភាព និងកិច្ចសហការប្រតិបត្តិការផ្នែកវិស័យនីតិកម្ម និងវិស័យការទូតសភាក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។

ក្នុងរយៈពេលនេះគណៈកម្មការនានានៃរដ្ឋសភាបានជួបសវនាការនិងពិភាក្សាការងារជាមួយអង្គការជាតិ និងអន្តរជាតិចំនួន១២លើក មានជាអាទិ៍៖

- លោកស្រី Jacqueline Wong ជាស្ថាបនិក និងជានាយិកាគ្រប់គ្រង Sequoia Group,
- លោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋគុយបា ប្រចាំកម្ពុជា
- ប្រតិភូយុវជននៃមជ្ឈមណ្ឌលប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍ និងសន្តិភាព
- លោកបណ្ឌិត Yong-deok Cho អគ្គលេខាធិការក្រុមប្រឹក្សាទឹកអាស៊ី (AWC)
- ឯកឧត្តម ANDEAS LAREM សមាជិកសភាអាល្លឺម៉ង់ (គណបក្សសង្គមប្រជាធិបតេយ្យSPD)
- គណៈប្រតិភូសមាជិកសភានៃបណ្តាប្រទេសស្កង់ឌីណាវី តំបន់Nordic អឺរ៉ុបខាងជើង
- ឯកឧត្តម **គឹម យាតដារ៉ាវិទ្ធ** នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសភាអាស៊ី
- ប្រតិភូសមាជិកសភាសហព័ន្ធអាល្លឺម៉ង់ និងមូលនិធិខុនរ៉ាដប្រចាំកម្ពុជា
- ឯកឧត្តម **ខាំចន្ទ សុដាប៉ាសឺត** (Khamchanh SODAPASEUTH) សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការកិច្ចការជនជាតិភាគតិចនៃរដ្ឋសភាឡាវ
- គណៈកម្មាធិការសម្របសម្រួលញត្តិ (Petitions Committee) នៃរដ្ឋសភាអាល្លឺម៉ង់ ដឹកនាំដោយលោកជំទាវ Martina Stamm-Fibich។
- លោកជំទាវ Ulku Kacaefe ឯកអគ្គរដ្ឋទូតតួកគីប្រចាំកម្ពុជា។

- គណៈកម្មការនានានៃរដ្ឋសភា បានចូលរួមកម្មវិធីផ្សេងៗ ដូចជា ៖ ពិធីផ្សព្វផ្សាយខ្លឹមសារអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស ពិធីសំណេះសំណាលជាមួយសិស្សជ័យលាភីប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០២៣ ពិធីទស្សនកិច្ចសិក្សារបស់និស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជាចំនួន១៣០នាក់ ដោយផ្តល់បទឧទ្ទេសស្តីពី «តួនាទីនិងភារកិច្ចរបស់រដ្ឋសភា» និងពិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ «ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល»។
- គណៈកម្មការនានានៃរដ្ឋសភាបានទៅបំពេញបេសកកម្មក្រៅប្រទេស ចំនួន ៦ លើក រួមមាន៖

- ចូលរួមកិច្ចប្រជុំក្រុមការងារ Task Force ស្តីពី Digital Library នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី
- ទស្សនកិច្ចការងារចំនួន ៣ លើក នៅសាធារណរដ្ឋកូរ៉េ អាស៊ែបៃហ្សង់ និងឥណ្ឌូនេស៊ី
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសមាជិកាសភាស្ត្រីអាយប៉ាប្រចាំឆ្នាំ២០២៤ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

- គណៈកម្មការនានានៃរដ្ឋសភា បានទទួលពាក្យបណ្តឹង សំណូមពរ និងសំណើផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន៦រឿង ដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី ការប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់តុលាការ និងសំណូមពរផ្សេងៗ។ គណៈកម្មការក៏បានចាត់ការពាក្យបណ្តឹង សំណូមពរ និងសំណើផ្សេងៗ តាមនីតិវិធីច្បាប់ ដោយបានធ្វើលិខិតអន្តរាគមន៍បញ្ជូនទៅក្រសួងស្ថាប័នមានសមត្ថកិច្ចធ្វើការដោះស្រាយចំនួន ៥រឿង និងកំពុងពិនិត្យសិក្សាចំនួន ១រឿង ព្រមទាំងបានទទួលលិខិតឆ្លើយតបអំពីលទ្ធផលដោះស្រាយរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចចំនួនមួយផងដែរ។

## IV-សកម្មភាពរបស់សមាជិក សមាជិការដ្ឋសភា

នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧ នេះសមាជិក សមាជិការដ្ឋសភាថ្នាក់ដឹកនាំរដ្ឋសភា និងថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការនានានៃរដ្ឋសភា បានបំពេញការងារតាមតួនាទី និងភារកិច្ចដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងការចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមណ្ឌលរាជធានី ខេត្តនានា និងសកម្មភាពផ្សេងៗយ៉ាងសកម្ម និងមានសកម្មភាពជាច្រើនផ្សេងៗទៀត។

ទូលបង្គំ ខ្ញុំ សូមអភ័យទោសចំពោះសមាជិក សមាជិការដ្ឋសភា ជាពិសេស សមាជិក សមាជិការដ្ឋសភា ដែលនៅក្រៅគណៈកម្មការជំនាញនានារបស់រដ្ឋសភា ដោយពុំអាចរៀបរាប់ក្នុងរបាយការណ៍សង្ខេបនេះ ប៉ុន្តែបានរាយការណ៍នៅក្នុងរបាយការណ៍លម្អិត ដូចបានចែកថ្វាយ និងជូនអង្គសភារួចហើយ។

**សេចក្តីសន្និដ្ឋានៈ**

នៅចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១ និងលើកទី២ នីតិកាលទី៧ ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ សម្តេច ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រគ្រប់រូប បានបំពេញការងារនៅតាមមូលដ្ឋាន និងនៅទូទាំងប្រទេសយ៉ាងសកម្មបំផុត ដើម្បីស្វែងយល់ពីសុខទុក្ខប្រជាពលរដ្ឋផ្ទាល់ ព្រមទាំងចូលរួមដោះស្រាយសំណូមពរនិងសំណើផ្សេងៗរបស់ប្រជាពលរដ្ឋ ដូចជា បញ្ហាគ្រោះរាំងស្ងួត ទីផ្សារកសិផល ដីធ្លី ជួយឧបត្ថម្ភដល់ប្រជាជនជួបការលំបាក ជួយអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ ចំនួន ៩៣៩លើក។

ទោះបីការងារចុះមូលដ្ឋានមមាញឹកយ៉ាងណាក្តី ក៏សមាជិករដ្ឋសភាទាំងអស់បានអញ្ជើញចូលរួមប្រជុំរដ្ឋសភាជាវិសាមញ្ញ ដោយបានអនុម័តច្បាប់ចំនួន ២ច្បាប់ បោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលចំនួន ៣រូប និងបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ២រូប។ ជាមួយនេះ គណៈកម្មការនានានៃរដ្ឋសភា បានអញ្ជើញសមាជិករាជរដ្ឋាភិបាលមកបំភ្លឺអំពីវិស័យទទួលខុសត្រូវរបស់ខ្លួន។ ក្នុងរយៈពេលនេះដែរ រដ្ឋសភានីតិកាលទី៧ បានបំពេញការងារការបរទេសយ៉ាងសកម្ម ដូចជាការជួបពិភាក្សាក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី និងចូលរួមកិច្ចប្រជុំអង្គការ

អន្តរជាតិនានា សំដៅពង្រឹងពង្រីក និងលើកកម្ពស់វិស័យការទូតសភា ដែលកិច្ចការនេះមានសារៈសំខាន់រួមចំណែកដល់ទំនាក់ទំនងចំណងមិត្តភាព និងសហប្រតិបត្តិជាមួយសភា និងរដ្ឋាភិបាលនៃប្រទេសនានាដៃគូអភិវឌ្ឍន៍ និងអង្គទូតបរទេសនានា។

ក្នុងនាមសម្ដេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា និងក្នុងនាមទូលបង្គំ ខ្ញុំផ្ទាល់ សូមសម្ដែងនូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រនិងវាយតម្លៃខ្ពស់ ចំពោះតំណាងរាស្ត្រទាំងអស់ដែលបានយកចិត្តទុកដាក់បំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មិនគិតពីនិន្នាការនយោបាយដោយបានតម្កល់នូវផលប្រយោជន៍ប្រជាពលរដ្ឋ និងឧត្តមប្រយោជន៍ប្រទេសជាតិជាធំ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះស្ថាប័នរដ្ឋទាំងអស់ ជាអាទិ៍ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយ**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលបានសហការល្អ បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងឱ្យគណៈកម្មការនានានៃរដ្ឋសភា គណៈប្រតិភូរដ្ឋសភា តំណាងរាស្ត្រទាំងអស់ បានជួបសំណេះសំណាល ប្រាស្រ័យការងារ និងសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមមណ្ឌលរាជធានី ខេត្តនានា។

នៅទីបញ្ចប់ ទូលបង្គំ ខ្ញុំ សូមថ្លែងនូវអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ និងសូមថ្វាយព្រះពរ និងជូនពរសព្វសាធុការពរ បវរសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ សម្ដេចព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តមទាំងអស់ សូមប្រកបនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ និងសូមអរគុណ!**